# សេចក្តីប្រកាសព័ត៌មានរួមរវាង
# ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសុខភាពពិភពលោក (WHO)

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មិនា ឆ្នាំ២០១៥

## ការទទួលស្គាល់ជាផ្លូវការថា ព្រះរាជាណាចក្រកម្ពុជាបានបំបាត់ជំងឺកញ្រ្ជិល ទាំងស្រុងនៅក្នុងឆ្នាំ២០១៥ ដោយអង្គការសុខភាពពិភពលោក តំបន់អាស៊ីប៉ាស៊ីហ្វិកខាងលិច

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៥ គណៈកម្មការវាយតំលៃនៃការបំបាត់ជំងឺកញ្រ្ជិលនៅតំបន់របស់អង្គការសុខភាពពិភពលោក បានទទួលស្គាល់ថា ព្រះរាជាណាច្រកម្ពុជាបានបំបាត់ជំងឺកញ្រ្ជិលទាំងស្រុង ព្រមទាំងកត់សម្គាល់ថា មិនមានករណីជំងឺកញ្រ្ជិល រកឃើញដោយមន្ទីរពិសោធន៍ ដែលត្រូវបានរាយការណ៍នៅក្នុងប្រទេសនេះ ចាប់តាំងពីខែ វិច្ឆិកា ឆ្នាំ២០១១ មក។ គណៈកម្មការនេះបានជួបប្រជុំគ្នានៅថ្ងៃទី ២៤-២៧ ខែមីនា នៅតំបន់រដ្ឋបាលពិសេសទីក្រុងម៉ាកាវ (សាធារណរដ្ឋប្រជាមានិតចិន) និងបានប្រកាសថា ប្រទេសកម្ពុជារួមជាមួយប្រទេសប្រ៊ុយណេដារូសាឡឹម និងប្រទេសជប៉ុន ទទួលបានជោគជ័យក្នុងការបំបាត់ជំងឺកញ្រ្ជិលទាំងស្រុងនៅក្នុងឆ្នាំ២០១៥។

"ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាសម្រេចបាននូវស្ថានភាពគ្មានជំងឺកញ្រ្ជិល ចូលរួមការកាត់បន្ថយអត្រាឈឺ និងមរណភាពរបស់កុមារជួយឲ្យប្រទេសកម្ពុជាសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សទី៤ " តាមប្រសាសន៍របស់ ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** រដ្ឋមន្រ្តីក្រសួងសុខាភិបាល "។

ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** ក៏បានសម្តែងនូវការដឹងគុណចំពោះការខិតខំប្រឹងប្រែងរបស់មន្រ្តីសុខាភិបាលទាំងអស់ ការចូលរួមរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ព្រមទាំងការជួយគាំទ្រយ៉ាងពេញទំហឹងពីដៃគូអភិវឌ្ឍន៍ ដែលបានធ្វើឲ្យប្រទេសកម្ពុជាសំរេចបាននូវសមិទ្ធិផលដ៏ធំធេងក្នុងការបំបាត់ជំងឺកញ្រ្ជិល។

លោកវេជ្ជបណ្ឌិត **Dong il Ahn** តំណាងអង្គការសុខភាពពិភពលោក ប្រចាំប្រទេសកម្ពុជាបានអបអរសាទរចំពោះរាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឆ្ពោះទៅរកការបំបាត់ជំងឺកញ្រ្ជិលក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមក។ លោកបានបញ្ជាក់បន្ថែមថា "ជំហានបន្ទាប់របស់យើងគឺត្រូវពង្រឹងការតាមដានជម្ងឺ និងរក្សាឲ្យបាននូវភាពស៊ាំក្នុងចំណោមប្រជាជនកម្ពុជាឲ្យបានខ្ពស់ជានិច្ច "។

គណៈកម្មាធិការជាតិវាយតំលៃការបំបាត់ជំងឺកញ្រ្ជិលរបស់កម្ពុជាបានជួបប្រជុំគ្នាកាលពីខែវិច្ឆិកា ឆ្នាំ២០១៤ ដើម្បីពិនិត្យឯកសាររបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ។ គណៈកម្មាធិការនេះក៏បានសន្និដ្ឋានថា មានភស្តុតាងដ៏រឹងមាំជាច្រើន ដែលអះអាងថា ការឆ្លងនៃមេរោគជំងឺកញ្រ្ជិលត្រូវបានកាត់ផ្តាច់ ដូច្នេះប្រទេសកម្ពុជាបានសម្រេចបំបាត់ការឆ្លងមេរោគកញ្រ្ជិលអស់រយៈពេល៣៦ខែរួចមកហើយ និងមានលទ្ធភាពស្នើឲ្យមានការវាយតំលៃដោយគណៈកម្មាធិការវាយតំលៃរបស់អង្គការសុខភាពពិភពលោកប្រចាំតំបន់។

ជំងឺកញ្ជ្រឹលជាជំងឺឆ្លងខ្លាំងជាងគេបំផុតនៅទូទាំងពិភពលោក ដោយបានសម្លាប់មនុស្សប្រមាណជា៤០០នាក់ ជារៀងរាល់ថ្ងៃ ដែលភាគច្រើនជាកុមារដែលមានអាយុក្រោម ៥ឆ្នាំ ឬ ១៦នាក់ បានស្លាប់ជារៀងរាល់ម៉ោង។ កម្ពុជាគឺជាប្រទេសមានជំងឺកញ្ជ្រឹលជាប្រចាំអស់រយៈពេលច្រើនឆ្នាំមកហើយ។ រហូតមកដល់ឆ្នាំ១៩៩៨ ជំងឺកញ្ជ្រឹលជាមូលហេតុនាំមុខនៃការឈឺ និងការស្លាប់ក្នុងចំណោមជំងឺឆ្លងនៅក្នុងប្រទេសកម្ពុជា។ យើងបានដឹងថាជំងឺកញ្ជ្រឹលជាបញ្ហាសុខភាពចំបង នៅទូទាំងប្រទេស ពិសេសនៅក្នុងតំបន់ដាច់ស្រយាល តាមព្រំដែន ក្នុងចំណោមប្រជាជនជនជាតិភាគតិច និងប្រជាជន ចំណាកស្រុក និងនៅតំបន់ក្រីក្រ។ ក្រសួងសុខាភិបាលបានផ្តល់ថ្នាំបង្ការជំងឺកញ្ជ្រឹលក្នុងឆ្នាំ១៩៨៦ និងបានចាប់ផ្តើមតាមដានករណីជំងឺកញ្ជ្រឹលជាប្រចាំចាប់តាំងពីឆ្នាំ១៩៩៨ និងបានបញ្ចូលថ្នាំបង្ការជំងឺកញ្ជ្រឹលដូសទី២ ក្នុងកំឡុងឆ្នាំ២០១២។ បន្ទាប់ពីការទទួលបានភាពជោគជ័យក្នុងការលុបបំបាត់ជំងឺគ្រុនស្វិតដៃជើង កម្មវិធីជាតិផ្តល់ថ្នាំបង្ការបានយកចិត្តទុកដាក់ដល់ការកាត់បន្ថយជំងឺកញ្ជ្រឹល និងជំងឺតេតាណូសលើមាតានិងទារក។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការក៏បានកំណត់គោលដៅបំបាត់ជំងឺកញ្ជ្រឹលក្នុងឆ្នាំ២០០៦ តាមរយៈការពង្រឹងសកម្មផ្តល់ថ្នាំបង្ការជាប្រចាំ តាមរយៈការធ្វើយុទ្ធនាការផ្តល់វ៉ាក់សាំងការពារជំងឺកញ្ជ្រឹលជាច្រើនលើក ក៏ដូចជាយុទ្ធនាការផ្តល់វ៉ាក់សាំងកញ្ជ្រឹល វ៉ាក់សាំងការពារកញ្ជ្រឹល-ស្អូចរួមគ្នា ដើម្បីបង្កើនអត្រាគ្របដណ្តប់ថ្នាំបង្ការ និងបង្កើនភាពស៊ាំដល់កុមារដើម្បីធានាថា កុមារអាចការពារនឹងជំងឺកញ្ជ្រឹលបាន។

ការសម្រេចបានជាស្ថាបពរនូវស្ថានភាពគ្មានជំងឺកញ្ជ្រឹល ប្រទេសកម្ពុជាបានចូលរួមជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកខាងលិច ចំនួន០៦ប្រទេសផ្សេងទៀត រួមមានប្រទេសអូស្ត្រាលី ប្រទេសប្រ៊ុយណេដារូសាឡឹម ប្រទេសជប៉ុន ទីក្រុងម៉ាកាវ (សាធារណរដ្ឋប្រជាមានិតចិន) ប្រទេសម៉ុងហ្គោលី និងសាធារណរដ្ឋកូរ៉េ ដែលជាប្រទេសដែលសម្រេចបានជាស្ថាពរនូវស្ថានភាពគ្មានជំងឺកញ្ជ្រឹល ។

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

សាស្ត្រាចារ្យ សាន់ ចន្ទ័សឿន កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្រសួងសុខាភិបាល
ទូរស័ព្ទលេខ: ០១២ ៩៣៣ ៣៨៤
អ៊ីមែល : workmoh@gmail.com

វេជ្ជបណ្ឌិត សាហ្វិគុល ហូសសេន មន្ត្រីបច្ចេកទេសផ្តល់ថ្នាំបង្ការ អង្គការសុខភាពពិភពលោក នៅកម្ពុជា
ទូរស័ព្ទលេខ : ០១២៥១៧៧៥៥
អ៊ីមែល : hossains@wpro.who.int

**ព័ត៌មានបន្ថែម សូមស្វែងរកនៅក្នុងអស័យដ្ឋានខាងក្រោម ៖**

Health topic: Measles
http://www.who.int/mediacentre/factsheets/fs286/en/
Global Vaccine Action Plan 2011-2020
http://www.who.int/immunization/global_vaccine_action_plan/GVAP_doc_2011_2020/en/
Q&A: Measles verification
http://www.wpro.who.int/mediacentre/releases/2014/FINAL_RVCQA11Mar.pdf?ua=1